## IEEFA៖ ការស្វែងយល់អំពីឱកាស និងបញ្ហាប្រឈមនៃមហិច្ឆតា LNG របស់ប្រទេសកម្ពុជា

*គម្រោងប្រើប្រាស់ LNG អាចគំរាមកំហែងដល់សន្តិសុខថាមពល តម្លៃ និងគោលដៅថាមពលកកើតឡើងវិញ ប្រសិនបើពុំមានការពិចារណាដោយប្រុងប្រយ័ត្នលើហានិភ័យទីផ្សារ និងហេដ្ឋារចនាសម្ព័ន្ធ*

**(IEEFA អាស៊ី)៖** ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ កំណើនសេដ្ឋកិច្ច និងការផ្គត់ផ្គង់ថាមពលអគ្គិសនីយ៉ាងឆាប់រហ័សនៅកម្ពុជា បានជំរុញឱ្យមានការប្រែប្រួលគួរឱ្យកត់សម្គាល់នៅក្នុងប្រព័ន្ធអគ្គិសនីរបស់ប្រទេសកម្ពុជា។ បើទោះបីជាប្រទេសនេះមានប្រវត្តិពឹងផ្អែកលើប្រេង វារីអគ្គិសនី និងធ្យូងថ្មសម្រាប់ផលិតអគ្គិសនីក្តី ផែនការថាមពលបានគិតគូរអំពីដំណាក់កាលថ្មីមួយនៃការអភិវឌ្ឍដែលផ្តោតលើថាមពលកកើតឡើងវិញ និងការដាក់ឱ្យប្រើឧស្ម័នធម្មជាតិរាវ (LNG)។

របាយការណ៍ចុងក្រោយរបស់វិទ្យាស្ថានវិភាគសេដ្ឋកិច្ចថាមពល និងហិរញ្ញវត្ថុ (IEEFA) បានឱ្យដឹងថា ទោះបីជាមានការរំពឹងខ្ពស់ចំពោះការនាំចូល LNG ក៏ដោយ ក៏ការប្រឈមនឹងទីផ្សារឧស្ម័នសកល និងហានិភ័យផ្នែកហេដ្ឋារចនាសម្ព័ន្ធ អាចគំរាមកំហែងដល់តម្លៃ និងសន្តិសុខនៃប្រព័ន្ធថាមពលកម្ពុជាដែរ ប្រសិនបើមិនមានយុទ្ធសាស្ត្រដ៏ប្រុងប្រយ័ត្ននោះទេ។

លោក Sam Reynolds សហអ្នកនិពន្ធរបាយការណ៍ និងជាប្រធានផ្នែកស្រាវជ្រាវ LNG/ឧស្ម័ន នៃ IEEFA អាស៊ី មានប្រសាសន៍ថា “ករណីប្រទេសកម្ពុជាបង្ហាញអំពីបញ្ហាប្រឈមយ៉ាងច្បាស់លាស់នៃការអភិវឌ្ឍខ្សែសង្វាក់តម្លៃនៃការបំប្លែងពី LNG ទៅជាថាមពល។ ដោយសារឧស្ម័នមិនមានប្រវត្តិដើរតួនាទីនៅក្នុងប្រព័ន្ធថាមពលរបស់ប្រទេសនេះ ការណែនាំឱ្យមានការនាំចូល LNG និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធ អាចបណ្តាលឱ្យប្រេងឥន្ធនៈ និងថាមពលមានតម្លៃខ្ពស់ សម្រាប់សេដ្ឋកិច្ចកម្ពុជា”។

ផែនការថាមពលផ្លូវការរបស់កម្ពុជា មានគោលដៅផលិតថាមពល ៧០% នៃថាមពលរបស់ប្រទេសកម្ពុជាពីប្រភពកកើតឡើងវិញនៅត្រឹមឆ្នាំ២០៣០ ដែលចំនួននេះកើនឡើងពី ៥០% នៅឆ្នាំ២០២៣។ បន្ថែមពីលើទំហំថ្មីរបស់ថាមពលពន្លឺព្រះអាទិត្យ និងថាមពលខ្យល់ រដ្ឋាភិបាលមានបំណងបញ្ចប់ការផលិតថាមពលអគ្គិសនីដើរដោយ LNG យ៉ាងតិច ៩០០ មេហ្គាវ៉ាត់នៅក្នុងទសវត្សរ៍ឆ្នាំ២០៣០ ដើម្បីបំពេញកំណើនតម្រូវការអគ្គិសនី និងធ្វើឱ្យមានតុល្យភាពនៃការផលិតថាមពលកកើតឡើងវិញ។ បច្ចុប្បន្ន មានសំណើបង្កើតរោងចក្រថាមពលដើរដោយ LNG កម្លាំង ២.០០០ មេហ្គាវ៉ាត់ នៅក្នុងប្រទេសនេះ ជាមួយនឹងការព្យាករណ៍មួយចំនួនដែលបានធ្វើចំណោលថាកម្លាំងថាមពល LNG អាចឈានដល់ ៨.៧០០ មេហ្គាវ៉ាត់ត្រឹមឆ្នាំ២០៥០។

### ការតម្រង់ទិសចំពោះការប្រែប្រួលនៃទីផ្សារ LNG សកល

របាយការណ៍ IEEFA គូសបញ្ជាក់អំពីចំណុចសំខាន់ៗជាច្រើន ដែលអ្នកបង្កើតគោលនយោបាយកម្ពុជា និងភាគីពាក់ព័ន្ធផ្នែកឧស្សាហកម្មត្រូវពិចារណា ទាក់ទងនឹងការនាំចូល LNG។ ទីមួយ តម្លៃ LNG បានឡើងខ្ពស់ខ្លាំងក្នុង រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារការប្រែប្រួលយ៉ាងឆាប់រហ័សនៅលើទីផ្សារពិភពលោក រួមជាមួយផលប៉ះពាល់ដែលមិនសមាមាត្រចំពោះសេដ្ឋកិច្ចដែលកំពុងអភិវឌ្ឍន៍ នៅអាស៊ី។

លោក Christopher Doleman សហអ្នកនិពន្ធរបាយការណ៍ IEEFA និងជាអ្នកឯកទេសផ្នែក LNG/ឧស្ម័ន នៃ IEEFA អាស៊ី មានប្រសាសន៍ថា “ការប្រែប្រួលទីផ្សារយ៉ាងឆាប់រហ័ស និងការកើនឡើងនៃតម្លៃចាប់ពីឆ្នាំ២០២០ បានធ្វើឱ្យបណ្តាប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ជាច្រើន គ្មានលទ្ធភាពទិញ LNG បាន ដែលបណ្តាលឱ្យមានកង្វះប្រេងឥន្ធនៈ និងថាមពល ដែលជាហេតុនាំឱ្យសន្តិសុខថាមពលចុះអន់ថយ។

លោក Doleman មានប្រសាសន៍បន្ថែមទៀតថា “ប្រទេសកម្ពុជា ដែលជាអ្នកចំណូលថ្មីនៅក្នុងទីផ្សារនេះ ជាមួយអំណាចចរចាតិចតួច ភាពមិនច្បាស់លាស់នៃតម្រូវការ LNG រួមជាមួយការប្រើប្រាស់មានកម្រិត អាចជួបការលំបាកក្នុងការទទួលបានការផ្គត់ផ្គង់ដែលមានតម្លៃសមរម្យ នៅក្នុងទីផ្សារពិភពលោកផងដែរ”។

តម្លៃខ្ពស់របស់ LNG អាចបង្កើនទំហំចំណាយក្នុងការនាំចូលប្រេងឥន្ធនៈរបស់ប្រទេសកម្ពុជា ដោយសារ LNG នាពេលថ្មីៗនេះ មានតម្លៃពីរទៅបីដងនៃតម្លៃធ្យូងថ្ម។ របាយការណ៍ IEEFA រកឃើញថា ដំណើរការរោងចក្រថាមពលមួយដែលដើរដោយ LNG ដែលមានទំហំ ៩០០ មេហ្គាវ៉ាត់ នៅកម្រិតមូលដ្ឋាន អាចបណ្តាលឱ្យមានការចំណាយលើប្រេងឥន្ធនៈប្រចាំឆ្នាំរហូតដល់ ៧២១ លានដុល្លារអាមេរិក (២,៩៥ ទ្រីលានរៀល)។ ចំណាយនេះមិនរួមបញ្ចូលដើមទុន ចំណាយប្រតិបត្តិការ ឬចំណាយហិរញ្ញប្បទានរបស់រោងចក្រនោះទេ

ហើយវាលើសពីចំណាយលើការនាំចូលធ្យូងថ្មសរុបរបស់ប្រទេសនេះ នៅក្នុងឆ្នាំ២០២២ ដែលមានចំនួន ៥៥៥ លានដុល្លារ អាមេរិករួចទៅហើយ។

តម្លៃ LNG ខ្ពស់នឹងមានផលប៉ះពាល់ដោយប្រយោលលើតម្លៃថាមពលនៅកម្ពុជា ដែលរារាំងដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយអត្រាតម្លៃនេះ។ បើគិតតម្លៃប្រេងឥន្ធនៈបច្ចុប្បន្ន តម្លៃក្នុងការផលិតថាមពលអគ្គិសនីដោយប្រើប្រាស់ LNG អាចមានតម្លៃលើសប្រាំដងនៃតម្លៃអគ្គិសនីដែលផលិតដោយថាមពលពន្លឺព្រះអាទិត្យនៅក្នុងប្រទេសនេះនាពេលថ្មីៗ ស្របពេលដែលអត្រាតម្លៃអគ្គិសនីនៅប្រទេសនេះស្ថិតក្នុងចំណោមខ្ពស់ជាងគេបំផុតនៅអាស៊ី។

លើសពីនេះទៀត តម្លៃ LNG នៅក្នុងទីផ្សារពិភពលោក ទំនងជាមិនធ្លាក់ចុះទាបគ្រប់គ្រាន់សម្រាប់ប្រកួតប្រជែងជាមួយរោងចក្រថាមពលកកើតឡើងវិញ ឬរោងចក្រធ្យូងថ្មកម្រិតមូលដ្ឋាននៅប្រទេសកម្ពុជានោះទេ ដែលកត្តានេះធ្វើឱ្យតួនាទីរបស់រោងចក្រអគ្គិសនីដើរដោយ LNG នៅក្នុងល្បាយថាមពលមានភាពមិនច្បាស់លាស់។ ករណីសិក្សានៅក្នុងរបាយការណ៍បង្ហាញថា ប្រទេសដទៃទៀតនៅអាស៊ី ដូចជាប្រទេសវៀតណាម និង ប្រទេសហ្វីលីពីន ជាដើម កំពុងប្រឈមមុខនឹងផលប៉ះពាល់នៃការនាំចូល LNG ដែលមិនមានភាពប្រកួតប្រជែង ចំពោះតម្លៃអគ្គិសនី។

**ការថ្លឹងថ្លែងទៅលើ LNG រវាងសន្តិសុខថាមពល និងតម្លៃសមរម្យ**

តួនាទីមិនច្បាស់លាស់របស់រោងចក្រថាមពល LNG នៅក្នុងល្បាយថាមពលរបស់ប្រទេសកម្ពុជានឹងធ្វើឱ្យមានការលំបាកក្នុងការកំណត់ទំហំហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចសន្យា តាមវិធីដែលធានាបានទាំងសន្តិសុខថាមពល និងតម្លៃសមរម្យ។ ការសម្រេចបានការជ្រៀតចូលក្នុងអត្រា ៧០% នៃថាមពលកកើតឡើងវិញ អាចបង្កើនអត្រាប្រើប្រាស់នៅរោងចក្របំប្លែងថាមពលពី LNG ដែលមានកម្រិតទាបខ្លាំង និងមិនបិតបេរ ដើម្បីគាំទ្រដល់កិច្ចព្រមព្រៀងស្តីពីការផ្គត់ផ្គង់ LNG រយៈពេលវែង ក្នុងតម្លៃសមរម្យ។

លោក Reynolds មានប្រសាសន៍ថា “ដោយសារចំណាយខ្ពស់ និងតួនាទីមិនច្បាស់លាស់របស់រោងចក្រផលិតថាមពលពី LNG រដ្ឋាភិបាលទំនងជាប្រឈមមុខនឹងការសម្រេចចិត្តដ៏លំបាកចំពោះលទ្ធកម្ម LNG និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ”។

ឧទាហរណ៍ ប្រទេសកម្ពុជាអាចទិញ LNG ក្នុងរយៈពេលខ្លី ឬរយៈពេលវែង ប៉ុន្តែវិធីសាស្ត្រនីមួយៗពាក់ព័ន្ធនឹងការថ្លឹងថ្លែងដ៏សំខាន់រវាងសន្តិសុខថាមពល និងតម្លៃសមរម្យ។ ទីផ្សារទិញលក់ទំនិញភ្លាមៗ អាចមានហានិភ័យខ្ពស់ ក្នុងអំឡុងពេលមានការប្រែប្រួលទីផ្សារសកល ប៉ុន្តែកិច្ចសន្យារយៈពេលវែងអាចរងការពិន័យប្រាក់ជាច្រើន ប្រសិនបើប្រទេសកម្ពុជាមិនត្រូវការទំនិញ LNG។ លក្ខខណ្ឌនៃកិច្ចសន្យាដទៃទៀតក៏នឹងមានការថ្លឹងថ្លែង ស្រដៀងគ្នានេះដែរ។

លើសពីនេះទៀត ប្រទេសកម្ពុជាអាចជ្រើសរើសហេដ្ឋារចនាសម្ព័ន្ធ LNG ខ្នាតតូច ដែលរួមមានស្ថានីយនាំចូលខ្នាតតូច និងការកំណត់បរិមាណ LNG ជាកុងតឺន័រ ដោយសារតម្រូវការ LNG ទំនងជាមានទំហំតិចតួចនៅដំណាក់កាលដំបូងនៃការអភិវឌ្ឍខ្សែសង្វាក់តម្លៃ។ ទោះបីវាទាមទារដើមទុនតិចក៏ដោយ ក៏ហេដ្ឋារចនាសម្ព័ន្ធ LNG ខ្នាតតូច អាចធ្វើឲ្យតម្លៃ LNG ក្នុងមួយឯកតា មានតម្លៃខ្ពស់ខ្លាំងដែរដោយសារតែមិនមានសេដ្ឋកិច្ចវិមាត្រ។

ទន្ទឹមនឹងនោះ ថាមពលខ្យល់ និងថាមពលពន្លឺព្រះអាទិត្យនៅប្រទេសកម្ពុជា មានឱកាសដ៏ធំសម្រាប់រីកលូតលាស់ ព្រមទាំងមិនប៉ះពាល់ដល់ដំណើរការបណ្តាញអគ្គិសនីដែលមានស្រាប់។ ទោះបីជាយ៉ាងណាក៏ដោយ តម្លៃ LNG ដែលកំពុងបន្តហក់ឡើង អាចបង្អាក់ការវិនិយោគដែលចាំបាច់ ដើម្បីពង្រីកបណ្តាញអគ្គិសនី និងទំហំ ផលិតថាមពលកកើតឡើងវិញនាពេលអនាគត ដែលឈានទៅរកការជ្រើសរើសរវាងការបន្តប្រើហ្វូស៊ីលឥន្ធនៈ និងសមាហរណកម្មថាមពលស្អាត។

លោក Doleman មានប្រសាសន៍ថា “ការសម្រេចចិត្តទាំងនេះមានសារសំខាន់ចំពោះមហិច្ឆតា LNG របស់ប្រទេសកម្ពុជា។ ប្រសិនបើមិនមានយុទ្ធសាស្ត្រគ្រោងទុកជាមុនយ៉ាងប្រុងប្រយ័ត្នទេនោះ ការដាក់ឱ្យប្រើ LNG អាចកាត់បន្ថយការសម្រេចបាននូវគោលដៅម៉ាក្រូសេដ្ឋកិច្ច និងវិស័យថាមពលរបស់រដ្ឋាភិបាល និងប៉ះពាល់ដល់សមត្ថភាពរបស់កម្ពុជាក្នុងការសម្រេចគោលដៅថាមពលរយៈពេលវែងរបស់ខ្លួន”។

**អានរបាយការណ៍៖** ប្រទេសកម្ពុជានៅផ្លូវបំបែក៖ ការវាយតម្លៃសេដ្ឋកិច្ចលើផែនការផលិតថាមពលពី LNG

**ព័ត៌មានទំនាក់ទំនងរបស់អ្នកនិពន្ធ៖**

Sam Reynolds (sreynolds@ieefa.org)

Christopher Doleman (cdoleman@ieefa.org)

**ព័ត៌មានទំនាក់ទំនងសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ៖**

Alex Yu (ayu@ieefa.org)

**អំពីអ្នកនិពន្ធ៖**

**Sam Reynolds** ជាប្រធានផ្នែកស្រាវជ្រាវនៃវិទ្យាស្ថានវិភាគសេដ្ឋកិច្ចថាមពល និងហិរញ្ញវត្ថុ (IEEFA) ដែលផ្តោតលើហានិភ័យផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងអាកាសធាតុ ទាក់ទងនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឧស្ម័នធម្មជាតិ និងឧស្ម័នធម្មជាតិរាវ (LNG) នៅតំបន់អាស៊ី ដែលមានទីផ្សារកំពុងអភិវឌ្ឍន៍។ គាត់គឺជាអ្នកនិពន្ធអត្ថបទសិក្សាជាច្រើនទាក់ទងនឹងបរិវត្តកម្មចំពោះថាមពលកកើតឡើងវិញនៅក្នុងតំបន់ ហានិភ័យនៃទ្រព្យសម្បត្តិជាប់គាំងនៅក្នុងវិស័យឧស្ម័នធម្មជាតិ និងហានិភ័យផ្នែកម៉ាក្រូសេដ្ឋកិច្ច ទាក់ទងនឹងការពឹងផ្អែកកាន់តែខ្លាំងលើការនាំចូល LNG នៅក្នុងតំបន់។

**Christopher Doleman** គឺជាអ្នកឯកទេសផ្នែក LNG/ឧស្ម័ននៅអាស៊ី ដែលផ្តោតលើទំនាក់ទំនងផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងអាកាសធាតុក្នុងការអភិវឌ្ឍខ្សែសង្វាក់តម្លៃរបស់ឧស្ម័នធម្មជាតិនៅទូទាំងអាស៊ី។ កន្លងមក Chris បានចំណាយពេលប្រាំឆ្នាំនៅមជ្ឈមណ្ឌលស្រាវជ្រាវថាមពលអាស៊ីប៉ាស៊ីហ្វិក (APERC) ក្នុងប្រទេសជប៉ុន ដើម្បីកំណត់ឱកាសសហការក្នុងចំណោមសមាជិកនៃវេទិកាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក (APEC) ដើម្បីសម្រេចបាននូវគោលដៅថាមពលរួម។ ក្នុងនាមជាអតីតអ្នកវិភាគទីផ្សារ និងអ្នកបង្កើតគំរូថាមពល គាត់បានវិភាគអំពីរបៀបដែលការអភិវឌ្ឍគោលនយោបាយ ទីផ្សារថាមពល និងបច្ចេកវិទ្យា បង្កើតទ្រង់ទ្រាយនៃប្រព័ន្ធថាមពល និងប៉ះពាល់ដល់សន្តិសុខថាមពល។

**អំពី IEEFA៖**

វិទ្យាស្ថានវិភាគសេដ្ឋកិច្ចថាមពល និងហិរញ្ញវត្ថុ (IEEFA) ត្រួតពិនិត្យបញ្ហា ទាក់ទងនឹងទីផ្សារ និន្នាការ និងគោលនយោបាយថាមពល។ វិទ្យាស្ថានមានបេសកកម្មពន្លឿនបរិវត្តកម្មឆ្ពោះទៅរកសេដ្ឋកិច្ចថាមពលចម្រុះ ប្រកបដោយនិរន្តរភាព និងផលចំណេញ។ (www.ieefa.org)